


# ក្រមសីលធម៌របស់

# C&A

# សម្រាប់ការផ្គត់ផ្គង់ទំនិញ

កំណត់សម្គាល់៖ នេះគឺជាការបកប្រែពីអត្ថបទភាសាអង់គ្លេស។ ឯកសារដែលមានតម្លៃតាមផ្លូវច្បាប់គឺជាអត្ថបទដើមជាភាសាអង់គ្លេស។

- ខែ មេសា ឆ្នាំ ២០១៥ -

# សេចក្តីផ្តើម

## គំរូអាជីវកម្មរបស់ C&A គឺ ដើម្បីផ្តល់ជូននូវផលិតផលសម្លៀកបំពាក់ទាន់សម័យដែលមានគុណភាពខ្ពស់ក្នុងតម្លៃសមរម្យ។

យើងប្តេជ្ញាចិត្តក្នុងការធ្វើបែបនេះប្រកបដោយចិរភាព ដោយមានការគោរពមនុស្សជាតិ និងបរិស្ថានផង និងប្រកាន់ខ្ជាប់តាមស្តង់ដារសុចរិតភាពអាជីវកម្មខ្ពស់។ យើងមានការជឿជាក់យ៉ាងមុតមាំថា នេះគឺជាវិធីតែមួយគត់ដែល C&A និងអ្នកផ្គត់ផ្គង់របស់ខ្លួនអាចបន្តទទួលបានជោគជ័យក្នុងរយៈពេលយូរអង្វែង។ ក្រមសីលធម៌សម្រាប់ការផ្គត់ផ្គង់ទំនិញ (“ក្រមសីលធម៌”)បរិយាយអំពីអ្វីដែល C&A រំពឹងទុកពីអ្នកផ្គត់ផ្គង់ទាក់ទងនឹងការប្រតិបត្តិតាមច្បាប់ ការអនុវត្តពលកម្ម ការអនុវត្តការងារផ្នែកបរិស្ថាន និងការប្រឆាំងនឹងអំពើពុករលួយ។ ការរំពឹងទុកដែលទាក់ទងនឹងបញ្ហាផ្សេងៗ ដូចជា ស្តង់ដារគុណភាព ស្តង់ដារផលិតផល និងសេចក្តីណែនាំការបញ្ជូនទំនិញមានរៀបរាប់នៅក្នុងគោលការណ៍ និងគោលការណ៍ណែនាំផ្សេងទៀត។ លក្ខខណ្ឌតម្រូវទាំងឡាយនៅក្នុងក្រមសីលធម៌នេះ មានពន្យល់បន្ថែមទៀតនៅក្នុងគោលការណ៍ណែនាំគាំទ្រដល់ក្រមសីលធម៌។ លក្ខខណ្ឌតម្រូវត្រូវបានអនុវត្តចំពោះអ្នកផ្គត់ផ្គង់ទាំងអស់ដែលផលិតទំនិញសម្រាប់ C&A[1]។ វាជាការសំខាន់ណាស់ដែលត្រូវកត់សម្គាត់ថា បទបញ្ញត្តិទាំងឡាយនៅក្នុងក្រមសីលធម៌នេះបង្កើតបានជាស្តង់ដារអប្បបរមាមួយ មិនមែនអតិបរមាឡើយ។ C&Aរំពឹងទុកថា អ្នកផ្គត់ផ្គង់មានគោលបំណងសម្រាប់ការកែលម្អលក្ខខណ្ឌការងារ និងការអនុវត្តការងារផ្នែកបរិស្ថានជាបន្តបន្ទាប់។

1. រួមទាំងអង្គភាពផលិតកម្ម ក្រុមហ៊ុនដែលជាសាខា បុត្រសម្ព័ន្ធ និងភ្នាក់ងារ។ លក្ខខណ្ឌទាំងនេះ មិនត្រឹមតែអនុវត្តចំពោះផលិតកម្មសម្រាប់ C&A ប៉ុណ្ណោះទេ ថែមទាំងអនុវត្តចំពោះផលិតកម្មសម្រាប់ភាគីទីបីផ្សេងទៀតផងដែរ។

# ល័ក្ខខ័ណ្ឌតម្រូវ

## C&A ប្រកាន់ខ្ជាប់តាមគោលការណ៍ទាំងដប់នៃកតិកាសញ្ញាជាសាកលរបស់អង្គការសហប្រជាជាតិ (UN Global Compact)។

C&A រំពឹងទុកថាអ្នកផ្គត់ផ្គង់ធ្វើប្រតិបត្តិការរបស់ខ្លួនប្រកបដោយការទទួលខុសត្រូវ និងខិតខំធ្វើយ៉ាងណាដើម្បីការពារមនុស្សជាតិ និងបរិស្ថាន។

តារាងខាងក្រោមនេះផ្តល់ជូននូវសេចក្តីសង្ខេបអំពីល័ក្ខខ័ណ្ឌតម្រូវទាំងឡាយនៅក្នុងក្រមសីលធម៌នេះ។

### សេចក្តីសង្ខេបអំពីល័ក្ខខ័ណ្ឌតម្រូវ

| | |
|---|---|
| 1. ការប្រតិបត្តិតាមច្បាប់ | • ប្រតិបត្តិតាមច្បាប់ជាតិ និងច្បាប់ជាធរមានផ្សេងៗគ្រប់ពេលវេលា<br>• គោរពកម្មសិទ្ធិបញ្ញា |
| 2. ពលកម្ម | • គ្មានពលកម្មកុមារ<br>• គ្មានការរើសអើងនៅក្នុងការងារ<br>• គ្មានពលកម្មដោយបង្ខំ<br>• គោរពសេរីភាពនៃសមាគម និងកិច្ចចរចារួម<br>• គ្មានការប្រព្រឹត្តចំពោះខ្លួនដែលមានលក្ខណៈឃោរឃៅ ឬអមនុស្សធម៌<br>• បរិយាកាសការងារដែលមានសុវត្ថិភាព និងមានអនាម័យ<br>• ការពិចារណាជាពិសេសសម្រាប់ក្រុមងាយរងគ្រោះ<br>• ការងារត្រឹមត្រូវតាមច្បាប់<br>• ប្រាក់ឈ្នួលសម្រាប់ការរស់នៅ ទូទាត់ឲ្យបានទាន់ពេលវេលា<br>• គ្មានម៉ោងធ្វើការច្រើនហួសហេតុ |
| 3. បរិស្ថាន | • ការប្រតិបត្តិតាមល័ក្ខខ័ណ្ឌច្បាប់<br>• ការគ្រប់គ្រងលើការអនុវត្តការងារផ្នែកបរិស្ថាន<br>• ការកែលម្អភាពសក្តិសិទ្ធិនៃថាមពល និងទឹក<br>• ការកាត់បន្ថយកាកសំណល់ និងការបំភាយទៅក្នុងបរិយាកាស<br>• ការកាត់បន្ថយសារធាតុគីមីដែលបង្កគ្រោះថ្នាក់នៅក្នុងសង្វាក់ផ្គត់ផ្គង់ |
| 4. ការប្រឆាំងអំពើពុករលួយ | • គ្មានអំពើសូកប៉ាន់ និងអំពើពុករលួយ |

# 1. ការប្រតិបត្តិតាមច្បាប់

- អ្នកផ្គត់ផ្គង់ត្រូវតែប្រតិបត្តិតាមច្បាប់ជាតិ និងច្បាប់ជាធរមានផ្សេងៗគ្រប់ពេលវេលា។
- នៅពេលបទបញ្ញត្តិនៃច្បាប់ និងក្រមសីលធម៌ចែងអំពីកម្មវត្ថុតែមួយ អ្នកផ្គត់ផ្គង់ត្រូវតែប្រតិបត្តិតាមបទបញ្ញត្តិនោះ ដែលផ្តល់កិច្ចការពារខ្ពស់ទៅលើកម្មករ ឬបរិស្ថាន។
- អ្នកផ្គត់ផ្គង់ត្រូវតែធានាថា មានការគោរពកម្មសិទ្ធិបញ្ញា ហើយមិនត្រូវមានការផ្តល់ជូន ឬផលិតច្បាប់ចម្លងទាំងឡាយណាដែលខុសច្បាប់ឡើយ។

# 2. ពលកម្ម

ល័ក្ខខ័ណ្ឌតម្រូវនៅក្នុងផ្នែកនេះ ផ្អែកទៅលើស្តង់ដារនៃអង្គការពលកម្មអន្តរជាតិ កម្មវិធីប្រតិបត្តិតាមសង្គមជាសាកល (Global Social Compliance Programme) និងក្រមមូលដ្ឋានផ្តួចផ្តើមគំនិតពាណិជ្ជកម្មត្រឹមត្រូវតាមសីលធម៌ (Ethical Trade Initiative Base Code)។

C&A គោរពសិទ្ធិមនុស្ស និងស្វែងរកការចៀសវាងនូវការចូលដៃនៅក្នុងការរំលោភបំពានសិទ្ធិមនុស្ស។ C&A រំពឹងថាអ្នកផ្គត់ផ្គង់គោរពសិទ្ធិមនុស្សរបស់កម្មករ និងប្រកាន់ខ្ជាប់តាមល័ក្ខខ័ណ្ឌតម្រូវទាំងឡាយនៅក្នុងផ្នែកនេះ។

## 2.1. ពលកម្មកុមារ

- កម្មករត្រូវមានអាយុយ៉ាងតិច 16 ឆ្នាំ ឬអាយុច្រើនជាងនេះ ប្រសិនបើមានការតម្រូវដោយច្បាប់ក្នុងស្រុក រួមទាំងបទបញ្ញត្តទាំងឡាយសម្រាប់ការអប់រំជាកាតព្វកិច្ច។
- កម្មករដែលអនុវត្តការងារប្រកបដោយគ្រោះថ្នាក់ ឬធ្វើការនៅពេលយប់ ត្រូវមានអាយុយ៉ាងតិច 18 ឆ្នាំ។

## 2.2. ការរើសអើង

- អ្នកផ្គត់ផ្គង់មិនត្រូវពាក់ព័ន្ធ គាំទ្រ ឬបណ្តោយឲ្យមានការរើសអើងនៅក្នុងការងារ[2] ឡើយ។
- មូលដ្ឋានតែមួយគត់សម្រាប់ការធ្វើឲ្យខុសគ្នារវាងកម្មករ ត្រូវតែជាសមត្ថភាព និងចេតនាក្នុងការធ្វើការងារ ជាជាងលក្ខណៈសម្បត្តិផ្ទាល់ខ្លួន[3]។

## 2.3. ពលកម្មដោយបង្ខំ

- កម្មករត្រូវតែធ្វើការរបស់ពួកគេដោយការស្ម័គ្រចិត្ត ដែលមានន័យថា រាល់ទម្រង់នៃពលកម្មដោយបង្ខំ រួមមាន ពលកម្មដែលតម្រូវឲ្យបង់ពន្ធ ចុះកិច្ចសន្យា និងជាប់ឃុំឃាំង ត្រូវបានហាមឃាត់។
- អ្នកផ្គត់ផ្គង់មិនត្រូវបំពានទៅលើជម្រើសដោយសេរីនៃការងារតាមរយៈការតម្រូវឲ្យមានការបង់ប្រាក់កក់ រក្សាទុកឯកសារបញ្ជាក់អត្តសញ្ញាណ ឬកាត់ប្រាក់ឈ្នួលឡើយ។
- អ្នកផ្គត់ផ្គង់ ត្រូវតែអនុញ្ញាតឲ្យកម្មករបញ្ចប់កិច្ចសន្យាការងាររបស់ពួកគេក្រោយពីមានការជូនដំណឹងសមហេតុផលមួយ។

---

2. រួមមាន ការជ្រើសរើស ការជួល ការបណ្តុះបណ្តាល ល័ក្ខខ័ណ្ឌការងារ ការចាត់តាំងការងារ ការផ្តល់សំណង ការដំឡើងឋានៈ វិន័យ ការបញ្ចប់កិច្ចសន្យាការងារ និងការចូលនិវត្តន៍។
3. លក្ខណៈសម្បត្តិផ្ទាល់ខ្លួនទាំងនេះរួមមាន ប៉ុន្តែមិនកំណត់ចំពោះ៖ ភេទ អាយុ សាសនា ស្ថានភាពគ្រួសារ ជាតិសាសន៍ វណ្ណៈសាវតាសង្គម ជំងឺ ពិការភាព ការមានផ្ទៃពោះ ជាតិពន្ធុ និងសញ្ជាតិដើម សញ្ជាតិ សមាជិកភាពនៅក្នុងអង្គការកម្មករ រួមមានដូចជាសហជីពពាណិជ្ជកម្ម និន្នាការនយោបាយ និងនិន្នាការភេទ។

## 2.4. សេរីភាពនៃសមាគម

- អ្នកផ្គត់ផ្គង់ត្រូវតែទទួលយកឥរិយាបថបើកទូលាយ និងសហការឆ្ពោះទៅរកការតំណាងឲ្យកម្មករ អនុញ្ញាតឲ្យកម្មករបង្កើត ឬចូលរួមសហជីពតាមជម្រើសរបស់ពួកគេ និងកិច្ចចរចាររួម។
- អ្នកផ្គត់ផ្គង់ត្រូវតែផ្តល់ជូនតំណាងកម្មករនូវសិទ្ធិចូលទៅកាន់កន្លែងធ្វើការ ដើម្បីអនុវត្តមុខងារតំណាងរបស់ពួកគេ។
- នៅពេលសិទ្ធិទទួលបានសេរីភាពនៃសមាគម និងកិច្ចចរចាររួម ត្រូវបានរឹតបន្តឹងដោយច្បាប់ អ្នកផ្គត់ផ្គង់ត្រូវតែសម្របសម្រួល ហើយមិនត្រូវរារាំងមិនឲ្យកម្មករបង្កើតទម្រង់ផ្សេងទៀតនៃការតំណាងកម្មករ និងកិច្ចចរចារឡើយ។
- អ្នកផ្គត់ផ្គង់ត្រូវតែអនុវត្តយន្តការបណ្តឹងតវ៉ាអំពីល័ក្ខខ័ណ្ឌការងារប្រកបដោយប្រសិទ្ធភាព ដើម្បីដោះស្រាយវិវាទឧស្សាហកម្មផ្ទៃក្នុង និងបណ្តឹងទាំងឡាយរបស់និយោជិត។

## 2.5. ការប្រព្រឹត្តចំពោះខ្លួនដែលមានលក្ខណៈឃោរឃៅ និងអមនុស្សធម៌

- អ្នកផ្គត់ផ្គង់ត្រូវតែប្រព្រឹត្តចំពោះខ្លួនកម្មករដោយភាពថ្លៃថ្នូរ និងការគោរព ហើយមិនត្រូវពាក់ព័ន្ធ ឬបណ្តោយឲ្យមានការសម្លុតធ្វើបាប[4] ការយាយីការបំភិតបំភ័យ អំពើហិង្សា ការធ្វើទណ្ឌកម្មលើរាងកាយ ឬការរំលោភបំពានគ្រប់ប្រភេទ[5] ឡើយ។
- អ្នកផ្គត់ផ្គង់ត្រូវតែបង្កើតនីតិវិធីវិន័យជាលាយលក្ខណ៍អក្សរ ពន្យល់នីតិវិធីទាំងនោះដោយប្រើពាក្យច្បាស់លាស់ទៅកាន់កម្មកររបស់ខ្លួន និងរក្សាទុកកំណត់ត្រានៃវិធានការវិន័យទាំងអស់។
- អ្នកផ្គត់ផ្គង់ត្រូវតែធ្វើឲ្យប្រាកដថា វិធានការវិន័យមានសមាមាត្រ ហើយមិនរួមបញ្ចូលនូវការដាក់ទណ្ឌកម្មលើរាងកាយ ឬផ្លូវចិត្តឡើយ។

## 2.6. សុខភាព និងសុវត្ថិភាព

- អ្នកផ្គត់ផ្គង់ត្រូវតែផ្តល់កន្លែងធ្វើការដែលមានសុវត្ថិភាព និងមានអនាម័យ មានពន្លឺ កម្តៅ និងខ្យល់ចេញចូលគ្រប់គ្រាន់។
- អ្នកផ្គត់ផ្គង់ត្រូវតែមានការប្រុងប្រយ័ត្នជាមុនដើម្បីបង្ការគ្រោះថ្នាក់ និងការរងរបួសទៅលើសុខភាពមិនឲ្យកើតឡើងនៅអំឡុងពេលធ្វើការ តាមរយៈការធានាឲ្យមានការចាប់កាន់ និងទុកដាក់សារធាតុគីមីប្រកបដោយសុវត្ថិភាព សុវត្ថិភាពនៃគ្រឿងចក្រ និងគ្រឿងបរិក្ខារ សុវត្ថិភាពអគ្គិសនី សុវត្ថិភាពភាពរឹងមាំ និងស្ថេរភាពនៃអគារ រួមមានអគារលំនៅដ្ឋានដែលផ្តល់ជូន និងតាមរយៈការផ្តល់ជូននូវការការពារប្រឆាំងនឹងអគ្គីភ័យឲ្យបានគ្រប់គ្រាន់។
- អ្នកផ្គត់ផ្គង់ត្រូវតែផ្តល់ជូនកម្មករជាមួយនឹងការបណ្តុះបណ្តាលអំពីសុខភាព និងសុវត្ថិភាពឲ្យបានទៀងទាត់ រួមមានដូចជា ការគ្រប់គ្រងកាកសំណល់ និងការចាប់កាន់សារធាតុគីមី និងសម្ភារៈគ្រោះថ្នាក់ផ្សេងៗ។
- អ្នកផ្គត់ផ្គង់ត្រូវតែផ្តល់នូវសិទ្ធិប្រើប្រាស់អគារបង្គន់អនាម័យ ទឹកស្អាត ហើយប្រសិនបើអាចអនុវត្តបាន អគារអនាម័យសម្រាប់រៀបចំ និងទុកដាក់ម្ហូបអាហារ។
- នៅពេលណាមានការផ្តល់ជូន អន្តេវាសិកដ្ឋានត្រូវតែមានលក្ខណៈស្អាត មានសុវត្ថិភាព និងឆ្លើយតបទៅនឹងសេចក្តីត្រូវការមូលដ្ឋានរបស់កម្មករ។

## 2.7. កិច្ចការពារជនងាយរងគ្រោះ

- អ្នកផ្គត់ផ្គង់ត្រូវតែផ្តល់ការពិចារណាពិសេសទៅលើសិទ្ធិរបស់ជនងាយរងគ្រោះដោយសារការអនុវត្តពលកម្មដែលមានលក្ខណៈរំលោភបំពាន ដូចជា ស្ត្រី កម្មករបម្រើតាមផ្ទះ កម្មកររបស់ទីភ្នាក់ងារ កម្មករបណ្តែត និងកម្មករចំណាកស្រុក។
- អ្នកផ្គត់ផ្គង់ដែលជួលកម្មករបម្រើតាមផ្ទះត្រូវតែប្រកាន់ខ្ជាប់តាម គោលការណ៍ណែនាំសម្រាប់ការប្រើប្រាស់កម្មករបម្រើតាមផ្ទះរបស់ C&A ដែលមានដាក់បញ្ចូលនៅក្នុងគោលការណ៍ណែនាំគាំទ្រដល់ក្រមសីលធម៌។

---

4. រួមទាំងការយាយីផ្លូវភេទ។

5. រួមទាំងការរំលោភបំពានលើរាងកាយ ផ្លូវចិត្ត និងពាក្យសម្តី។

## 2.8. ការងារត្រឹមត្រូវតាមច្បាប់

- អ្នកផ្គត់ផ្គង់ត្រូវចូលរួមជាមួយកម្មករដោយផ្អែកទៅលើទំនាក់ទំនងការងារដែលមានការទទួលស្គាល់ ដែលត្រូវបានបង្កើតឡើងតាមរយៈច្បាប់ និងការអនុវត្តរបស់ជាតិ។
- អ្នកផ្គត់ផ្គង់មិនត្រូវព្យាយាមចៀសវាងកាតព្វកិច្ចច្បាប់ដែលកើតចេញពីទំនាក់ទំនង[6] នេះឡើយ។

## 2.9. ប្រាក់ឈ្នួល

- អ្នកផ្គត់ផ្គង់ត្រូវតែផ្តល់សំណងដល់កម្មករតាមរយៈការទូទាត់ប្រាក់ឈ្នួល ប្រាក់ឈ្នួលក្រៅម៉ោង អត្ថប្រយោជន៍ និងការសុំច្បាប់ឈប់សម្រាកដោយមានប្រាក់ឈ្នួល ដែលឆ្លើយតប ឬលើសពីស្តង់ដារអប្បបរមាផ្លូវច្បាប់ និង/ឬកម្រិតគោលរបស់ឧស្សាហកម្ម ដែលជានិច្ចកាលគឺខ្ពស់ជាង។
- អ្នកផ្គត់ផ្គង់ត្រូវតែផ្តល់សំណងដល់កម្មករនូវប្រាក់ឈ្នួលក្រៅម៉ោងក្នុងអត្រាខ្ពស់មួយ មិនតិចជាង 125% នៃអត្រាប្រាក់ឈ្នួលធម្មតា ឬខ្ពស់ជាងប្រសិនបើច្បាប់តម្រូវ។
- ប្រាក់ឈ្នួល និងការផ្តល់សំណង[7] ត្រូវតែទូទាត់ឲ្យបានទៀងទាត់ទាន់ពេលវេលា និងគ្រប់គ្រាន់ដើម្បីបំពេញតាមសេចក្តីត្រូវការមូលដ្ឋាន និងផ្តល់ប្រាក់ចំណូលតាមការសម្រេចចិត្តខ្លះសម្រាប់កម្មករ និងក្រុមគ្រួសាររបស់ពួកគេ។
- អ្នកផ្គត់ផ្គង់មិនត្រូវធ្វើការកាត់ប្រាក់ណាមួយចេញពីប្រាក់ឈ្នួល ដែលពុំមានចែងដោយច្បាប់ ឬជាវិធានការវិន័យឡើយ។
- អ្នកផ្គត់ផ្គង់ត្រូវតែផ្តល់ជូនកម្មករនូវព័ត៌មានជាលាយលក្ខណ៍អក្សរ និងអាចយល់បានអំពីល័ក្ខខ័ណ្ឌការងាររួមទាំងប្រាក់ឈ្នួល មុនពេលចាប់ផ្តើមការងារ និងអំពីសេចក្តីលម្អិតនៃប្រាក់ឈ្នួលរបស់ពួកគេរៀងរាល់ពេលទូទាត់ជូនពួកគេ។

## 2.10. ម៉ោងធ្វើការ

- អ្នកផ្គត់ផ្គង់ត្រូវតែកំណត់ម៉ោងធ្វើការស្តង់ដារដោយកិច្ចសន្យា តាមចំនួនមួយដែលស្របគ្នាជាមួយនឹងច្បាប់ជាតិ ឬកិច្ចព្រមព្រៀងរួមដែលជាអតិបរមាមានបន្ថែមម៉ោងលើស 48 ម៉ោងក្នុងមួយសប្តាហ៍។
- អ្នកផ្គត់ផ្គង់ត្រូវតែប្រើការងារបន្ថែមម៉ោងប្រកបដោយការទទួលខុសត្រូវ មិនត្រូវស្នើឲ្យធ្វើការបន្ថែមម៉ោងជាទៀងទាត់ ហើយត្រូវទទួលស្គាល់ថា ការងារបន្ថែមម៉ោងគឺជាការស្ម័គ្រចិត្ត ដូច្នេះហើយមិនត្រូវបង្ខិតបង្ខំកម្មករឲ្យធ្វើការបន្ថែមម៉ោងឡើយ។
- ម៉ោងធ្វើការមិនអាចលើសពី 60 ម៉ោងក្នុងរយៈពេលប្រាំពីរថ្ងៃឡើយ លើកលែងតែស្ថិតនៅក្នុងកាលៈទេសៈដែលអាចលើកលែងបាន និងមិនអាចដឹងជាមុនបាន[8] ។
- អ្នកផ្គត់ផ្គង់ត្រូវតែអនុញ្ញាតឲ្យកម្មករសម្រាក មានថ្ងៃឈប់សម្រាកយ៉ាងហោចណាស់មួយថ្ងៃក្នុងរយៈពេលប្រាំពីរថ្ងៃ[9] និងឈប់សម្រាកតាមការកំណត់ដោយច្បាប់។

---

6. ឧទាហរណ៍ តាមរយៈកម្មវិធីហាត់ការដែលត្រូវបានអនុវត្តដោយពុំត្រឹមត្រូវ ឬការប្រើកិច្ចសន្យាមានពេលកំណត់ច្រើនហួសហេតុពេក។
7. សម្រាប់ម៉ោងធ្វើការតាមស្តង់ដារ ពោលគឺ ពុំមានការបន្ថែមម៉ោង។
8. ហើយលុះត្រាណាតែល័ក្ខខ័ណ្ឌទាំងឡាយដូចតទៅនេះមានការឆ្លើយតបប៉ុណ្ណោះ៖ 1) អនុញ្ញាតដោយច្បាប់ជាតិ 2) អនុញ្ញាតដោយកិច្ចព្រមព្រៀងរួម និង 3) មានកិច្ចការពារសុខភាព និងសុវត្ថិភាពកម្មករ។
9. ឬឈប់សម្រាកពីរថ្ងៃរៀងរាល់ 14 ថ្ងៃម្តង នៅពេលច្បាប់ជាតិអនុញ្ញាត។

# 3. បរិស្ថាន

C&A ជឿជាក់ថា ការអនុវត្តការងារផ្នែកបរិស្ថានបានល្អ គឺជាបុរេល័ក្ខខ័ណ្ឌមួយសម្រាប់ភាពជោគជ័យនាពេលអនាគតក្នុងនាមជាឧស្សាហកម្មមួយ។ ដូច្នេះកន្លងមក C&A រំពឹងថាអ្នកផ្គត់ផ្គង់ប្រតិបត្តិឲ្យបានលើសពីនេះ និងគ្រប់គ្រងការអនុវត្តការងារផ្នែកបរិស្ថានជាលក្ខណៈសកម្មប្រយុទ្ធ។ នៅពេលចាំបាច់ C&A នឹងធ្វើការជិតស្និទ្ធជាមួយអ្នកផ្គត់ផ្គង់ ដើម្បីជួយដល់ពួកគេក្នុងការសម្រេចឲ្យបាននូវការប្រកាន់ខ្ជាប់តាមក្រមសីលធម៌។

## 3.1. ការប្រតិបត្តិតាមច្បាប់

- អ្នកផ្គត់ផ្គង់ត្រូវតែប្រតិបត្តិតាមច្បាប់ និងបទបញ្ញាថ្នាក់មូលដ្ឋាន និងថ្នាក់ជាតិស្តីពីកិច្ចការពារបរិស្ថាន និងមានគោលបំណងឆ្លើយតបទៅនឹងស្តង់ដារការពារបរិស្ថានអន្តរជាតិ។
- អ្នកផ្គត់ផ្គង់ត្រូវតែទទួលបាននូវលិខិតអនុញ្ញាតផ្នែកបរិស្ថានទាំងអស់ ហើយរក្សាឲ្យលិខិតទាំងនោះទាន់សម័យជានិច្ច។

## 3.2. ការគ្រប់គ្រងការអនុវត្តការងារផ្នែកបរិស្ថាន

- អ្នកផ្គត់ផ្គង់ត្រូវតែមានប្រព័ន្ធគ្រប់គ្រងបរិស្ថាន[10] មួយនៅនឹងកន្លែង ហើយត្រូវចាត់តាំងការទទួលខុសត្រូវចំពោះការអនុវត្តការងារផ្នែកបរិស្ថានដល់តំណាងថ្នាក់គ្រប់គ្រងជាន់ខ្ពស់ម្នាក់។
- អ្នកផ្គត់ផ្គង់ត្រូវតែវាស់ស្ទង់ការប្រើប្រាស់ថាមពល និងទឹក ការបំភាយ និងការបង្ហូរចូលទៅក្នុងបរិស្ថាន និងការចោលកាកសំណល់ និងការផ្សព្វផ្សាយព័ត៌មាននេះជូន C&A តាមការស្នើសុំ។
- អ្នកផ្គត់ផ្គង់ត្រូវតែដាក់បញ្ចូលហេតុប៉ះពាល់បរិស្ថានទៅក្នុងការសម្រេចចិត្តអាជីវកម្ម ចាត់វិធានការវឌ្ឍនភាពមួយឆ្ពោះទៅកាន់ការកែលម្អការអនុវត្តការងារផ្នែកបរិស្ថាន និងតម្រូវដូចគ្នាពីអ្នកផ្គត់ផ្គង់ និងអ្នកម៉ៅការបន្តរបស់ពួកគេ។

## 3.3. ការប្រើប្រាស់ធនធាន និងបម្រែបម្រួលអាកាសធាតុ

- អ្នកផ្គត់ផ្គង់ត្រូវតែចាត់វិធានការបន្តកែលម្អភាពសក្តិសិទ្ធិនៃថាមពលនៅក្នុងអគារ ការដឹកជញ្ជូន និងផលិតកម្ម ហើយត្រូវខិតខំឲ្យអស់ពីលទ្ធភាពក្នុងការប្រើប្រាស់ប្រភពថាមពលដែលអាចបង្កើតឡើងវិញបាន ឬមានកំហាប់កាបូនតិចតួច។
- អ្នកផ្គត់ផ្គង់ដែលមានដំណើរការសើម (wet processes) ត្រូវតែចាត់វិធានការកែលម្អភាពសក្តិសិទ្ធិនៃទឹកជាបន្តបន្ទាប់។
- អ្នកផ្គត់ផ្គង់ត្រូវតែខិតខំឲ្យអស់ពីលទ្ធភាពក្នុងការធានាថា ការសម្រេចចិត្តជាវរបស់ខ្លួនមិនរួមចំណែកដល់ការកាប់បំផ្លាញព្រៃឈើ ការប្រព្រឹត្តឃោរឃៅទៅលើសត្វ ឬហេតុប៉ះពាល់អវិជ្ជមានទៅលើប្រព័ន្ធអេកូឡូស៊ីដែលងាយរងគ្រោះ ឬពពួកសត្វដែលរងគ្រោះថ្នាក់ ។[11]។

10. ប្រព័ន្ធគ្រប់គ្រងបរិស្ថានគឺជាសំណុំគោលការណ៍ជាលាយលក្ខណ៍អក្សរ ឧបករណ៍ធ្វើផែនការ និងនីតិវិធីក្នុងការវាស់ស្ទង់ គ្រប់គ្រង និងរាយការណ៍អំពីការអនុវត្តការងារផ្នែកបរិស្ថាន។
11. តាមការកំណត់ដោយ CITES និងបញ្ជីក្រហមរបស់អង្គការអន្តរជាតិអភិរក្សធនធានធម្មជាតិ(IUCN)។

## 3.4. កាកសំណល់ និងការបំភាយ

- អ្នកផ្គត់ផ្គង់ត្រូវតែចាត់វិធានការកាត់បន្ថយកាកសំណល់តាមរយៈការរចនា និងភាពសក្តិសិទ្ធិនៃប្រតិបត្តិការ និងសម្របសម្រួលការប្រើប្រាស់ឡើងវិញ និងការកែច្នៃឡើងវិញតាមដែលអាចធ្វើបាន។

- អ្នកផ្គត់ផ្គង់ត្រូវតែធ្វើប្រព្រឹត្តកម្មទឹកស្អុយឲ្យបានត្រឹមត្រូវមុនពេលបង្ហូរចេញ ត្រូវពិសោធន៍ទឹកស្អុយទៅតាមការតម្រូវដើម្បីឆ្លើយតបទៅនឹងស្តង់ដារប្រតិបត្តិបង្ហូរទឹកចេញថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន ហើយត្រូវចែករំលែកទិន្នន័យគុណភាពទឹកស្អុយជាមួយអ្នកពាក់ព័ន្ធតាមការស្នើសុំពី C&A។
- អ្នកផ្គត់ផ្គង់ត្រូវចាត់វិធានការកាត់បន្ថយការបំពុលដោយសំឡេង និងការបំភាយចូលទៅក្នុងអាកាស ដី និងទឹកក្រោមដី។

## 3.5. សារធាតុគីមីដែលបង្កគ្រោះថ្នាក់

- អ្នកផ្គត់ផ្គង់ត្រូវធ្វើការជាមួយ C&A និងអ្នកផ្គត់ផ្គង់របស់ពួកគេឆ្ពោះទៅរកការលុបបំបាត់នូវសារធាតុបង្កគ្រោះថ្នាក់ពីសង្វាក់ផ្គត់ផ្គង់។

# 4. ការប្រឆាំងអំពើពុករលួយ

C&A រំពឹងថាអ្នកផ្គត់ផ្គង់ប្រកាន់ខ្ជាប់តាមស្តង់ដារសីលធម៌ខ្ពស់នៅក្នុងការអនុវត្តអាជីវកម្ម។

- អ្នកផ្គត់ផ្គង់ត្រូវប្រតិបត្តិតាមច្បាប់ជាធរមានស្តីពីការប្រឆាំងនឹងអំពើសូកប៉ាន់ និងអំពើពុករលួយ។

- អ្នកផ្គត់ផ្គង់មិនត្រូវផ្តល់ជូន ទូទាត់ រៃអង្គាស ឬទទួលសំណូក រួមទាំងថ្លៃឈ្នួលសម្របសម្រួល។

- អ្នកផ្គត់ផ្គង់ត្រូវតែមានគោលការណ៍ និងនីតិវិធីប្រឆាំងនឹងអំពើពុករលួយនៅនឹងកន្លែង ហើយត្រូវពិនិត្យមើលវាឡើងវិញឲ្យបានទៀងទាត់ដើម្បីធានាថាវាដំណើរការប្រកបដោយប្រសិទ្ធភាព។

# ការធានានូវការប្រកាន់ខ្ជាប់តាមក្រម សីលធម៌

**C&A ទទួលស្គាល់ថា វាអាចជាបញ្ហាប្រឈមក្នុងការសម្រេចបាននូវការប្រតិបត្តិពេញលេញតាមក្រមសីលធម៌ ប៉ុន្តែជឿជាក់ថា នេះជារឿងសំខាន់សម្រាប់ភាពជោគជ័យពាណិជ្ជកម្មនាពេលអនាគតរបស់ C&A និងអ្នកផ្គត់ផ្គង់របស់ខ្លួន។**

ការប្រកាន់ខ្ជាប់តាមក្រមសីលធម៌ មិនមែនមិនសំខាន់ជាងការឆ្លើយតបតាមស្តង់ដារគុណភាព ឬលក្ខខណ្ឌក្នុងការបញ្ជូនទំនិញរបស់យើងឡើយ។ C&A នឹងប្រឹងប្រែងឲ្យអស់ពីលទ្ធភាពក្នុងការធ្វើការជាមួយអ្នកផ្គត់ផ្គង់ទាំងឡាយណាដែលបើកទូលាយ ស្មោះត្រង់ និងប្តេជ្ញាចិត្តចំពោះការកែលម្អជាបន្តបន្ទាប់ ហើយនឹងគាំទ្រដល់ពួកគេឲ្យសម្រេចតាមលក្ខខណ្ឌតម្រូវ។

## 1. ការគ្រប់គ្រងការអនុវត្តការងារ

- អ្នកផ្គត់ផ្គង់ត្រូវតែមានប្រព័ន្ធគ្រប់គ្រងដែលមានប្រសិទ្ធភាពមួយ ដើម្បីគ្រប់គ្រងជាលក្ខណៈសកម្មប្រយុទ្ធទៅលើការប្រកាន់ខ្ជាប់តាមក្រមសីលធម៌ ហើយត្រូវចាត់តាំងការទទួលខុសត្រូវចំពោះការប្រតិបត្តិតាមទៅឲ្យតំណាងថ្នាក់គ្រប់គ្រងជាន់ខ្ពស់ម្នាក់។

- អ្នកផ្គត់ផ្គង់ត្រូវតែធ្វើឲ្យកម្មករបានដឹងអំពីលក្ខខណ្ឌតម្រូវនៃក្រមសីលធម៌ ហើយត្រូវបណ្តុះបណ្តាលអ្នកគ្រប់គ្រង និងអ្នកមើលការខុសត្រូវរបស់ខ្លួនអំពីវិធីសម្រេចឲ្យបាននូវការប្រតិបត្តិតាមក្រមសីលធម៌។

- អ្នកផ្គត់ផ្គង់ត្រូវតែធ្វើការវាយតម្លៃផ្ទៃក្នុងឲ្យបានទៀងទាត់។

- អ្នកផ្គត់ផ្គង់ត្រូវតែទទួលបានការអនុញ្ញាតពី C&A សម្រាប់គ្រប់អង្គភាពផលិតកម្មទាំងអស់ ទោះជារបស់ផ្ទាល់ខ្លួនក្តី ឬម៉ៅការបន្តក្តី មុននឹងចាប់ផ្តើមផលិតកម្ម។ ការប្រើប្រាស់អង្គភាពផលិតកម្មណាមួយដោយពុំមានការអនុញ្ញាតត្រូវបានហាមឃាត់ជាដាច់ខាត។

- អ្នកផ្គត់ផ្គង់មិនអាចម៉ៅការបន្តនូវផ្នែកណាមួយនៃដំណើរការផលិតកម្មដោយពុំមានការយល់ព្រមជាលាយលក្ខណ៍អក្សរជាមុនពី C&A ឡើយ ហើយលុះត្រាណាតែបន្ទាប់ពីក) អ្នកម៉ៅការបន្តបានព្រមព្រៀងប្រតិបត្តិតាមក្រមសីលធម៌នេះ និង ខ) អ្នកម៉ៅការបន្តបានជាប់សវនកម្មមួយ។

- អ្នកផ្គត់ផ្គង់ត្រូវទទួលខុសត្រូវចំពោះការធានានូវការប្រតិបត្តិតាមក្រមសីលធម៌ដោយអ្នកម៉ៅការបន្ត។

## 2. ការត្រួតពិនិត្យ និងតម្លាភាព

- អ្នកផ្គត់ផ្គង់ត្រូវតែអនុញ្ញាតឲ្យ C&A និង/ឬតំណាងរបស់ខ្លួនធ្វើការវាយតម្លៃ ទោះដោយមានការជូនដំណឹងក្តី ឬពុំមានការជូនដំណឹងក្តី។
- អ្នកផ្គត់ផ្គង់ត្រូវតែមានការសហការ និងមានតម្លាភាពនៅអំឡុងពេលវាយតម្លៃ ហើយត្រូវផ្តល់សិទ្ធិទទួលបានដោយពុំមានការរឹតបន្តឹងលើកម្មករនូវ កំណត់ត្រា កន្លែងធ្វើការ និងអន្តេវាសិកដ្ឋាន ប្រសិនបើមាន។
- អ្នកផ្គត់ផ្គង់ត្រូវតែអនុញ្ញាតឲ្យមានការសម្ភាសន៍កម្មករនៅកន្លែងឯកជន ហើយមិនត្រូវបង្ហាត់កម្មករអំពីរបៀបឆ្លើយសំណួរផ្សេងៗឡើយ។
- អ្នកផ្គត់ផ្គង់ត្រូវតែរក្សាទុកកំណត់ត្រាទាំងស្រុង និងត្រឹមត្រូវ[12] ដើម្បីឲ្យការប្រតិបត្តិតាមអាចវាយតម្លៃបានប្រកបដោយប្រសិទ្ធភាព ហើយពុំត្រូវគ្រប់គ្រងលើព័ត៌មាន ឬធ្វើឲ្យខុសពីការពិតនូវរាល់ទិដ្ឋភាពណាមួយនៃប្រតិបត្តិការរបស់ខ្លួនឡើយ។
- អ្នកផ្គត់ផ្គង់ត្រូវតែអនុញ្ញាតឲ្យ C&A ផ្សព្វផ្សាយឈ្មោះ និងទីតាំងនៃអ្នកផ្គត់ផ្គង់ និងអង្គភាពផលិតកម្ម ព្រមទាំងព័ត៌មានអំពីការអនុវត្តការងាររបស់ពួកគេក្រោមក្រមសីលធម៌នេះទៅឲ្យភាគីទីបី។
- អ្នកផ្គត់ផ្គង់ត្រូវតែផ្តល់ជំនួយដល់ C&A និង/ឬតំណាងរបស់ខ្លួនក្នុងការអនុវត្តសវនកម្មលើអ្នកផ្គត់ផ្គង់ ឬអ្នកម៉ៅការបន្តរបស់ពួកគេតាមការស្នើសុំរបស់ C&A។

## 3. បរិស្ថាន

- C&A មានប្រព័ន្ធលើកឡើងអំពីកំហុសដោយរក្សាការសម្ងាត់មួយនៅនឹងកន្លែងហៅថា Fairness Channel ដែលតាមរយៈនេះ អ្នកពាក់ព័ន្ធ រួមទាំងអ្នកផ្គត់ផ្គង់ កម្មកររោងចក្រ និងនិយោជិតរបស់ C&A អាចរាយការណ៍អំពីអាកប្បកិរិយាខុសសីលធម៌ និងការរំលោភទៅលើក្រមសីលធម៌ទៅកាន់ថ្នាក់គ្រប់គ្រងកំពូលរបស់ C&A។
- ករណីមានការបំពានលើក្រមសីលធម៌នេះ C&A នឹងស្នើឲ្យអ្នកផ្គត់ផ្គង់អភិវឌ្ឍន៍ផែនការកែលម្អមួយដោយមានការគាំទ្រពី C&A តាមការចាំបាច់ ហើយត្រូវអនុវត្តវានៅក្នុងក្របខ័ណ្ឌពេលវេលាពិតប្រាកដមួយ ដែលអាចប្រែប្រួលអាស្រ័យទៅលើលក្ខណៈនៃការបំពាននោះ។
- ករណីមានការបំពានខុសពីធម្មតា រួមមាន ប៉ុន្តែមិនកំណត់ចំពោះ ពលកម្មកុមារ ពលកម្មដោយបង្ខំ ឬជាប់ឃុំឃាំង អំពើសូកប៉ាន់ ការក្លែងបន្លំ ការប្រើប្រាស់សមាសភាពក្លែងក្លាយ និងការប្រើប្រាស់អង្គភាពផលិតកម្មដោយពុំមានការអនុញ្ញាត និង/ឬករណីនៅតែបន្តមិនអនុវត្តផែនការកែលម្អដែលបានឯកភាពគ្នាទេនោះ C&A រក្សាសិទ្ធិក្នុងការបញ្ចប់ទំនាក់ទំនងអាជីវកម្មជាមួយអ្នកផ្គត់ផ្គង់នោះ រួមទាំងការបដិសេធចោលនូវការបញ្ជាទិញដែលពុំទាន់បានធ្វើផងដែរ។
- C&A នឹងឲ្យអ្នកផ្គត់ផ្គង់ទទួលខុសត្រូវចំពោះរាល់ការខូចខាត និងចំណាយទាំងឡាយដែលបានទទួលរងដោយ C&A រួមទាំងការខាតបង់ប្រាក់ចំណូល និង/ឬប្រាក់ចំណេញដែលអាចជាលទ្ធផលនៃការបំពានទៅលើក្រមសីលធម៌ដោយអ្នកផ្គត់ផ្គង់ រួមទាំងអ្នកម៉ៅការបន្តរបស់ពួកគេផងដែរ។

C&A ចង់កសាងទំនាក់ទំនងយូរអង្វែងជាមួយអ្នកផ្គត់ផ្គង់ ដែលពិតជាមានការប្តេជ្ញាចិត្តក្នុងការធ្វើការរួមគ្នាឆ្ពោះទៅរកលក្ខខ័ណ្ឌពលកម្ម និងការអនុវត្តការងារផ្នែកបរិស្ថានកាន់តែប្រសើរឡើង ហើយនឹងជួយដល់ពួកគេជំនះរាល់បញ្ហាលំបាកទាំងឡាយដែលពួកគេអាចនឹងប្រឈម។ សម្រាប់ការបញ្ជាក់បន្ថែម និងការណែនាំសម្រាប់ការអនុវត្តក្រមសីលធម៌នេះ សូមមើលគោលការណ៍ណែនាំគាំទ្រដល់ក្រមសីលធម៌ដែលនឹងមានការបន្ទាន់សម័យយ៉ាងទៀងទាត់។

12. ឧទាហរណ៍ កំណត់ត្រាអំពីចំនួនម៉ោងធ្វើការ និងឯកសារអំពីតារាងប្រាក់ខែ។